**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

# ញត្តិគាំទ្រ

ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទូទាំងខេត្តកំពង់ធំ សូមគាំទ្រយ៉ាងពេញទំហឹងចំពោះជំហរយ៉ាងមឹងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងក្នុងឱកាសសំណេះសំណាលជាមួយសហគមន៍និស្សិត និងកម្មសិក្សាការីខ្មែរនៅប្រទេសជប៉ុនកាលពីថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៨ **អំពីការមិនដោះដូរអធិបតេយ្យជាតិ ជាមួយបរទេស ការមិនយកសន្តិភាពរបស់ប្រទេសទៅដោះដូរជាមួយជំនួយ** ហើយប្រមុខរដ្ឋាភិបាលបានបញ្ជាក់ជំហរយ៉ាងច្បាស់ថា៖ **កម្ពុជាត្រូវប្រឹងរស់ងើបឈរឡើងដើម្បីការពារឯករាជ្យភាពអធិបតេយ្យភាពរបស់ប្រទេស ការពារសន្តិភាពរបស់ប្រទេស** ។

ជំហរដ៏ម៉ឺងម៉ាត់របស់ សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល នេះ ជាវីរៈភាពស្នេហាជាតិមាតុភូមិ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា ៥២ បានចែងថា "រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ..." ។

ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទូទាំងខេត្តកំពង់ធំ សូមប្រកាសគាំទ្រ និងប្តេជ្ញាអនុវត្តយ៉ាងពេញទំហឹងនូវប្រសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ខាងលើនេះ ដែលមានចរិត និងស្មារតីជាគោលការណ៍រឹងដូចដែកថែបដោយ **"មិនយកអធិបតេយ្យ ឯករាជ្យជាតិ និងសន្តិភាពដូរជាមួយជំនួយ"** និង **"កម្ពុជាត្រូវមានសិទ្ធិអនុវត្តច្បាប់កម្ពុជា"** ។

រដ្ឋបាលខេត្តកំពង់ធំ សូមប្រកាសមិនគាំទ្រដាច់ខាត ចំពោះគោលជំហររបស់បុគ្គលមួយចំនួន មាននិន្នាការផ្ទុយ ដោយព្រមឱនក្បាលជាក់បរទេសដើម្បីជំនួយ ជាលេសលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជាដែលជារដ្ឋអធិបតេយ្យ។

ថ្ងៃអង្គារ ១៥រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

កំពង់ធំ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៨

**អភិបាល**

សុខ-ណុ